សេចក្តីថ្លែងការណ៍៖
បណ្តឹងស្តីពីការព្រួយបារម្ភអំពីការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធគម្រោងអភិវឌ្ឍ
ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជា ដាក់ជូនអង្គការសហប្រជាជាតិ

**Contacts - Regional:**
Ame Trandem, +66868822426, ame@internationalrivers.org, International Rivers
Maureen Harris, +918135999896, maureen@earthrights.org, EarthRights International
**Contacts - Cambodia:**
Meach Mean, +85575974112, meach.mean@hotmail.com, 3SPN (Lower Sesan 2)
Ith Mathoura, +855 12505686, thoura@samrethlawgroup.com, Samreth Law Group (Cheay Areng)

**ថ្ងៃអង្គារទី១៣ ខែមករា ឆ្នាំ២០១៥៖** ថ្ងៃនេះ អង្គការពាក់ព័ន្ធកម្ពុជា និងអន្តរជាតិ ដាក់ពាក្យបណ្តឹងមួយទៅអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដែលជាការព្រួយបារម្ភកាន់តែខ្លាំងឡើងពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សដែលបណ្តាលមកពីការអភិវឌ្ឍគម្រោងទំនប់វារីអគ្គិសនីពីរនៅក្នុងប្រទេសកម្ពុជា។ ពាក្យបណ្តឹងនេះគូសបញ្ជាក់អំពីទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលបច្ចុប្បន្នកំពុងដំណើរការសាងសង់នៅក្នុងខេត្តស្ទឹងត្រែង និងទំនប់ស្ទឹងជាយអារ៉ែង នៅខេត្តកោះកុង ដែលតាមសេចក្តីរាយការណ៍ថា ជិតទទួលបានការអនុម័តហើយ។ ពាក្យបណ្តឹងនេះ អំពាវនាវសុំឱ្យអ្នករាយការណ៍ពិសេសធ្វើការស៊ើបអង្កេត និងស្វែងរកដំណោះស្រាយចំពោះការរំលោភបំពានសិទ្ធិមនុស្សដែលកំពុងកើតឡើង និងដែលបម្រុងនឹងកើតឡើងទាក់ទងនឹងគម្រោងទាំងពីរនេះ។

តាមការស្ទង់មតិនាពេលថ្មីៗដោយគម្រោងអភិវឌ្ឍន៍ទំនប់ទន្លេសេសានក្រោម២ (LS2) បានលើកឡើងនូវកង្វល់អំពីការដាក់សម្ពាធ និងការគំរាមកំហែងលើអ្នកភូមិឲ្យយល់ព្រមតាមការស្ទង់មតិនិងតាមផែនការតាំងលំនៅថ្មីដែលបានស្នើឡើងនោះ ដោយឲ្យប្រជាពលរដ្ឋ ៥០០០នាក់ផ្លាស់ប្តូរទីតាំងរស់នៅ។

លោក មៀច មៀន អ្នកសម្របសម្រួលនៃបណ្តាញការពារទន្លេ-សពា (3SPN) ដែលជាអង្គការថ្នាក់មូលដ្ឋាននិងធ្វើការជាមួយសហគមន៍ដែលរងផលប៉ះពាល់ បានឱ្យដឹងថា "ជីវិតរបស់មនុស្សរាប់ពាន់នាក់នឹងត្រូវហិនហោច និងត្រូវបំផ្លាញដោយសារគម្រោងនេះ។ ទោះបីជាមានផលប៉ះពាល់ធ្ងន់ធ្ងរដោយសារគម្រោងរបស់ខ្លួនក៏ដោយ ក៏ពុំមានតម្លាភាពក្នុងការធ្វើសេចក្តីសម្រេចនោះឡើយ ហើយក៏មិនមានការពិគ្រោះយោបល់ពិតប្រាកដជាមួយសហគមន៍ដើម្បីឱ្យពួកគាត់បានបង្ហាញនូវក្តីកង្វល់របស់ពួកគាត់ឡើយ»។ " ដោយសារ ប្រជាជនជាច្រើនដែលត្រូវរងផលប៉ះពាល់ដោយទំនប់វារីអគ្គិសនីនេះជាជនជាតិដើមភាគតិច ដូច្នេះក្តីកង្វល់របស់ពួកគាត់ ក៏គប្បីត្រូវលើកឡើងជាលក្ខខណ្ឌពិចារណាមុនពេលដែលរដ្ឋាភិបាលសម្រេចបន្តដំណើរការទំនប់វារីអគ្គិសនីទន្លេសេសានក្រោម២នេះដែរ"។

ក្នុងពាក្យបណ្តឹងនេះ ក៏មានលើកឡើងអំពីការព្រួយបារម្ភចំពោះផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដែលគេមើលឃើញថា នឹងបង្កឡើងដោយគម្រោងទំនប់វារីអគ្គិសនីទន្លេសេសានក្រោម២

នៅក្នុងប្រទេសកម្ពុជានិងនៅក្នុងតំបន់ដែរ។ ទំនប់វារីអគ្គិសនីនេះនឹងកាត់បន្ថយជីវម៉ាស់ត្រី៩,៣% នៅក្នុងអាងទន្លេមេគង្គនិងបឹងទន្លេសាបទាំងមូល និងធ្វើឲ្យបាត់បង់យ៉ាងធ្ងន់ធ្ងរដល់ពូជត្រីជាង៥០ប្រភេទ។[i] លើសពីនេះទៀត បម្រែបម្រួលរំហូរទឹកនិងដីល្បាប់យ៉ាងច្រើននៅទន្លេមេគង្គនិងដៃទន្លេនេះ នឹងធ្វើឲ្យមានប៉ះពាល់ដល់ជលផល និងវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត ដែលលាតសន្ធឹងពីខ្សែទឹកខាងក្រោមរហូតដល់តំបន់ដីសណ្តទន្លេមេគង្គក្នុងប្រទេសវៀតណាម។[ii]

លោកស្រី Ame Trandem នាយកកម្មវិធីអាស៊ីអាគ្នេយ៍នៃអង្គការទន្លេអន្តរជាតិបានថ្លែងថា៖ “គម្រោងទំនប់វារីអគ្គិសនីនេះនឹងធ្វើឱ្យអន្តរាយដល់សន្តិសុខស្បៀងរបស់មនុស្សរាប់រយរាប់ពាន់នាក់ក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាង”។ “ជលផលទឹកសាបបង្កើតបានជាប្រភពអាហារប្រូតេអ៊ីនយ៉ាងសំខាន់ ហើយផលប៉ះពាល់ដែលបណ្តាលមកពីការបាត់បង់ផលនេសាទ ទៅលើសុខភាពនិងអាហារូបត្ថម្ភនេះគឺទំនងជាត្រូវបានរីករាលដាលនិងធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងកិច្ចអភិវឌ្ឍន៍ក្នុងតំបន់។ ដោយសារនេះគឺជាផ្នែកមួយនៃគម្រោងទំនប់វារីអគ្គិសនីដែលអាក្រក់បំផុតនៅក្នុងតំបន់ ហើយសិទ្ធិរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់មិនត្រូវបានគោរព ដូច្នេះវាច្បាស់ណាស់ថា ទំនប់វារីអគ្គិសនីនេះត្រូវមានការស៊ើបអង្កេតបន្ថែមទៀត និងគប្បីត្រូវបានលុបចោល”។

ប្រសិនបើ គម្រោងនេះបន្តដំណើរការទៅមុខ ដូច្នេះទំនប់ស្ទឹងជាយអារ៉ែងនឹងធ្វើឲ្យប្រជាពលរដ្ឋជនជាតិដើមភាគតិចប្រមាណ១៥០០នាក់ ដែលហៅតំបន់នេះថា ជាផ្ទះឬកន្លែងរបស់ពួកគាត់រស់នៅជាង៦០០ឆ្នាំមកហើយ ដោយបំផ្លាញប្រពៃណីនិងវប្បធម៌របស់ពួកគាត់។ គម្រោងនេះតាមការរំពឹងទុកថា នឹងផ្តល់ថាមពលអគ្គិសនីកម្រិតទាប ហើយបំផ្លាញបរិស្ថានយ៉ាងខ្លាំង និងបង្កការបំផ្លាញទៅលើប្រព័ន្ធអេកូឡូស៊ីគ្មានពីរនេះ ព្រមទាំងបំផ្លាញសត្វព្រៃកម្រ និងជិតផុតពូជសំខាន់ៗ នៅក្នុងជ្រលងភ្នំល្អៗ ដែលហ៊ុំព័ទ្ធដោយតំបន់ព្រៃការពារនៅតាមជួរភ្នំក្រវាញ។[iii]

ស លីណែត មេធាវីមកពី ក្រុមមេធាវីសំរិទ្ធ បាននិយាយថា "ប្រជាសហគមន៍អារ៉ែងមិនគាំទ្រគម្រោងនេះទេ"។ "ពួកគាត់មិនទាន់បានទទួលព័ត៌មានណាមួយពីរដ្ឋាភិបាលឬក្រុមហ៊ុន ឬពុំទាន់មានឱកាសដើម្បីពិភាក្សាជាមួយរដ្ឋាភិបាលឬក្រុមហ៊ុនអភិវឌ្ឍន៍នៅឡើយ។ ជាជនជាតិដើមភាគតិច តាមច្បាប់អន្តរជាតិ ពួកគាត់មានសិទ្ធិស្របច្បាប់ ក្នុងការយល់ព្រមដោយទទួលបានព័ត៌មានច្បាស់លាស់ និងដោយគ្មានការបង្ខិតបង្ខំជាមុន ហើយពួកគាត់កំពុងការពារសិទ្ធិរបស់ពួកគាត់ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធីយ៉ាងសកម្ម"។

រដ្ឋាភិបាលកម្ពុជា កំពុងដំណើរការ បង្កើនការអភិវឌ្ឍវារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជា ដោយមានគម្រោងទំនប់វារីអគ្គិសនីធំៗមួយចំនួន ត្រូវបានអនុវត្តរួចរាល់ហើយ និងមានគម្រោងជាច្រើនផ្សេងទៀត ត្រូវបានស្នើសុំ។ ទោះបីជា ទំនប់វារីអគ្គិសនីអាចនាំមកនូវផលប្រយោជន៍សេដ្ឋកិច្ច និងផលប្រយោជន៍ផ្សេងៗទៀតក៏ដោយ វាក៏បង្កឲ្យមានហានិភ័យខ្ពស់ណាស់ដែរ។

Maureen Harris ទីប្រឹក្សាច្បាប់ប្រចាំអង្គការ EarthRights International បានថ្លែងថា៖ "បច្ចុប្បន្ននេះ កម្ពុជាខ្វះក្របខ័ណ្ឌច្បាប់ពេញលេញសម្រាប់អនុវត្តក្នុងការអភិវឌ្ឍគម្រោងវារីអគ្គិសនីទ្រង់ទ្រាយធំ"។ "ជាពិសេស ក្របខណ្ឌច្បាប់ដូចជា គោលការណ៍ការពារសង្គមនិងបរិស្ថាន ដែលជាគោលការណ៍យ៉ាងចាំបាច់សម្រាប់ការពារប្រឆាំងនឹងផលប៉ះពាល់ដែលអាចបំផ្លាញបរិស្ថាន និងសិទ្ធិមនុស្ស។ រដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនអភិវឌ្ឍន៍គម្រោងនៅកម្ពុជាត្រូវតែធានាឱ្យបានថា មានគោលការណ៍ការពារបែបនេះសម្រាប់អនុវត្តន៍ ហើយត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍នេះមុនពេលធ្វើការសម្រេចចិត្ត ឬបន្តគម្រោងដែលអាចបង្កគ្រោះថ្នាក់ទាំងនេះ។ យើងសង្ឃឹមថា ពាក្យបណ្តឹងទៅអង្គការសហប្រជាជាតិនេះនឹងទទួលបានលទ្ធផលល្អ ដោយរដ្ឋាភិបាលកម្ពុជា ចាត់វិធានការសកម្ម ឆ្ពោះទៅរកការធានាថា មានតែគម្រោងទំនប់វារីអគ្គិសនីប្រកបដោយនិរន្តរភាពនិងដែលគោរពសិទ្ធិមនុស្សរបស់ប្រជាជនដែលរងផលប៉ះពាល់ប៉ុណ្ណោះ ត្រូវបានសាងសង់"។

សូមអានពាក្យបណ្តឹងទាំងស្រុង **នៅទីនេះ**។

---

[i] Ziv, Guy; Baran, Guy Eric; Nam, So; Ignacio Rodríguez-Iturbe, Ignacio and Levin, Simon A.; '*Trading-off fish biodiversity, food security, and hydropower in the Mekong River Basin'* Proceedings of the National Academy of Sciences of the United States of America, 28 January 2012.
[ii] Piman, T., Cochrane, T., Arias, M., Green, A., and Dat, N. "*Assessment of Flow Changes from Hydropower Development and Operations in Sekong, Sesan and Srepok Rivers of the Mekong Basin*" (2013) Journal of Water Resources Planning and Management, 139(6), 723–732.
[iii] Harbinson, Rod, 'Cambodia: indigenous protests repel dam builders - so far', *The Ecologist*, 28 July 2014.